# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន អ៊ីន ស៊ូ អា អឺភែរ៉ឺល ឯក

IN SOO AH APPAREL CO.,LTD

អាសយដ្ឋាន ភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ

## កំណត់ហេតុ

## ស្តីពីការព្រមព្រៀងព្យួរកិច្ចសន្យាការងារនិងនិតិវិធីក្នុងការបើកប្រាក់ឈ្នួល

-យោងតាមប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីរក្សាលំនឹងជីវភាពរបស់បងប្អូនកម្មករនិយោជិត និងធានានូវស្ថេរភាពអាជីវកម្មរបស់រោងចក្រដែលថមថយច្រវាក់ផលិតកម្មក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចសកល ក្រសួងសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រត្រូវធ្វើការពិភាក្សាគ្នាជាមួយតំណាងបងប្អូនកម្មករនិយោជិតដើម្បីកំណត់ការឆ្លាស់វេនគ្នាធ្វើការងារនៅពេលមានការព្យួរកិច្ចសន្យាការងារក្នុងរយៈពេលកំណត់ណាមួយដោយផ្អែកលើគោលការណ៍សមភាព។ បងប្អូនកម្មករនិយោជិតដែលត្រូវបានព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃ១ ខែ មេសា ឆ្នាំ ២០២៣ នឹងត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចខាងក្រោម៖

-យោងសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ ០២០/២៣ កប/ស ណ ន ខ ល ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូបដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល។

នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២៣ វេលាម៉ោង ១៣: ០០ នាទី មានការបើកអង្គប្រជុំមួយក្រោមអធិបតីលោក KIM SEUNGWAN ជានាយកក្រុមហ៊ុន និង លោកស្រី ហែម គីមហួង ជាលេខាកត់ត្រាបានបើកអង្គប្រជុំមួយស្តីពីការព្រមព្រៀងព្យួរកិច្ចសន្យាការងារនិងនិតិវិធីក្នុងការបើកប្រាក់ឈ្នួលដែលមានទីតាំងនៅក្រុមហ៊ុន អ៊ីន ស៊ូ អា អឺភែរ៉ឺល ឯក។

## សមាសភាពចូលរួមជាភ្ញៀវកិត្តិយសរួមមាន :

-លោក KIM SEUNGWAN តួនាទីជានាយកក្រុមហ៊ុន

-លោកស្រី ហែម គីមហួង តួនាទី ប្រធានរដ្ឋបាល

-ប្រធានក្រុម និងប្រធានផ្នែក

- តំណាងប្រតិភូបុគ្គលិកពេញសិទ្ធនិងជំនួយទាំងអស់

Scanned with CamScanner

ជាកិច្ចចាប់ផ្ដើមលោក KIM SEUNGWAN ជាប្រធានអង្គប្រជុំបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ប្រធានក្រុម ប្រធានផ្នែក ព្រមទាំងកម្មករនិយោជិតទាំងអស់ដែលបានចូលរួមក្នុងការសហការនេះ។ ក្នុងនាមលោក ជាប្រធានអង្គប្រជុំក៏បានបញ្ជាក់ផងដែរនូវគោលបំណងនៃកិច្ចប្រជុំ ដោយលោកនាយកបានបញ្ជាក់ថា ដោយសាគ្មានការបញ្ជាទិញពីអតិថិជននៅសហរដ្ឋអាមេរិកនិងប្រទេសផ្សេងៗទៀត ជាហេតុធ្វើឲ្យក្រុមហ៊ុនជួបនូវការលំបាកផ្នែកហិរញ្ញវត្ថុដែលក្រុមហ៊ុនចាំបាច់ត្រូវ ព្យួរការងារនិយោជិតគ្រប់ផ្នែកទាំងអស់ ។ គិតត្រឹមថ្ងៃទី 02 ខែ ឧសភា ឆ្នាំ ២០២៣ ក្រុមហ៊ុន អ៊ីន ស៊ូ អា អឺកែរឹល ឯក មានកម្មករនិយោជិតចំនួន ២៧៨ នាក់ ហើយចំនួនកម្មករនិយោជិតដែលនឹងត្រូវដាក់ពាក្យស្នើសុំព្យួរការងារមានចំនួន ២៧៨ នាក់ ក្នុងនោះមានកម្មករការនីចំនួន២៥៣នាក់ រយៈពេលនៃការព្យួរ ០២ ខែ ដោយគិតចាប់ពីថ្ងៃទី០២ ខែ ឧសភា ដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣។

-របៀបក្នុងការបើកប្រាក់ឈ្នួល

ក្រោយពីបានធ្វើការណែនាំយ៉ាងច្បាស់លាស់អំពីគោលការណ៍រួចហើយ អង្គប្រជុំបានមូលមតិគ្នាជាឯកច្ឆន្ទកំណត់ការបើកប្រាក់ឈ្នួលចំនួន ៦០ ដុល្លាអាមេរិកនៅថ្ងៃទី០២ ខែ ឧសភា ឆ្នាំ ២០២៣ និងថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ តាមរយៈធានាគារវីងផ្ញើរទៅលេខទូរសព្ទ័ដៃរបស់កម្មករនិយោជិតដែលនឹងត្រូវព្យួរការងារ។

កិច្ចពិភាក្សារការងារបានចប់សព្វគ្រប់នៅថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាសសោមនស្សរីករាយ និងស្និទស្នាលក្រៃលែងជាងទីបំផុត។

ថ្ងៃ ពុធ ១៥កើត ខែ ចេត្រ ឆ្នាំ ខាល ចត្វាស័ក ពស ២៥៦៦

ត្រូវនឹង ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២៣

| | |
|---|---|
| បានឃើញ និង ឯកភាព | លេខាកត់ត្រា |
| នាយកក្រុមហ៊ុន | ប្រធានរដ្ឋបាល |
| KIM SEUNGWAN | HEM KIMHONG |

ហត្ថលេខានិងស្នាមមេដៃប្រតិភូបុគ្គលិកពេញសិទ្ធ

| | | | |
|---|---|---|---|
| ឈៀ សាន | ហ៊ឹម ធី | ទ្រុក ឡាច | តៀ សុផល |
| ជិន សម្ភស្ស | ចឹម សារ៉ែន | ទុយ សាភ័ន | ឈឹម សុវណ្ណរចនា |

Scanned with CamScanner